# ការសំភាសន៍របស់បងប្រុស សំរិទ្ធិ សាម៉ន

កៈ អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ សំរិទ្ធិ សាម៉ន

## ការសង្ខេបប្រវត្តិរបស់ បងប្រុស សំរិទ្ធិ សាម៉ន

បងប្រុស សំរិទ្ធិ សាម៉ន មានអាយុ38ឆ្នាំនៅក្នុងឆ្នាំ2018 បងប្រុស សំរិទ្ធ សាម៉ន មានភេទប្រុស បងប្រុស សំរិទ្ធ សាម៉ន មានទីលំនៅបច្ចុប្បន្ននៅ ភូមិស្ទឹងជ្រៅស្ទឹង ឃុំដើមមាន ក្រុងតាខ្មៅ ខេត្តកណ្ដាល។

កៈ ចឹងជាដំបូងខ្ញុំអរគុណបងដែរបានអោយខ្ញុំពិភាក្សាពីប្រវត្តិរបស់បង ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗៗនឹងអោយពួកគាត់ បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយនឹង ប្រវត្តិរបស់ដូនតាចឹងនៅពេលដែរខ្ញុំបានពិភាក្សាជាមួយបង ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងសំរាប់បងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេបង?

ខៈ បាទមិនអីទេ

កៈ បាទបងបាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍បងខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរ ខ្ញុំបានសំភាសន៍បងគឺនៅថ្ងៃទី6ខែ4 ឆ្នាំ2018ហើយការសំភាសន៍មួយនេះនឹងត្រូវបានធ្វើឡើងនៅ ភូមិអូរជ្រៅ ចុះឃុំអីគេដែរទៅបង?

ខៈ ភូមិស្ទឹងជ្រៅ

កៈ នៅភូមិស្ទឹងជ្រៅណាបង?

ខ៖ បាទៗៗនៅឃុំដើមមាន

ក៖ ប៉ុន្តែស្រុក នឹងគេហៅក្រុង?

ខ៖ នៅក្រុងតាខ្មៅ នឹងខេត្តកណ្តាល

ក៖ ក្រុងតាខ្មៅ នឹងខេត្តកណ្តាល
ចុះចឹងសំរាប់បងមានឈ្មោះពេញនឹងមានឈ្មោះអីគេដែរទៅបង?

ខ៖ ខ្ញុំមានឈ្មោះសំរិទ្ធិ សាម៉ន

ក៖ មានឈ្មោះសំរិទ្ធិ សាម៉ន ចុះមានឈ្មោះហៅក្រៅដែរទេបង?

ខ៖ អត់មានទេ

ក៖ ចុះកាលពីក្មេងនឹងមាននរណាហៅឈ្មោះបងអីផ្សេងដែរទេបង?

ខ៖ អត់មានទេ

ក៖ ចុះបងសព្វថ្ងៃនឹងបងអាយុប៉ុន្មានដែរបង?

ខ៖ ខ្ញុំអាយុ38ឆ្នាំនឹង

ក៖ ចឹងបងអាយុ38ឆ្នាំណបង ចុះបងកើតនៅថ្ងៃខែឆ្នាំណាដែរបងមានចងចាំទេ?

ខ៖ ខ្ញុំកើតនៅឆ្នាំ1979

ក៖ ចឹងនៅឆ្នាំ1979ហេដូចជាអាយុ?

ខ៖ កើតនៅឆ្នាំ1979នឹងអាយុ38 រឺមួយក៏អាយុ39ឆ្នាំទេនេះ

ក៖ ហ៎ា!!បងដូចជាបងអាយុ39ឆ្នាំហើយនឹងបង?

ខ៖ នឹងហើយអាយុ38ឆ្នាំទៅ39ឆ្នាំនឹងហាស

ក៖ បាទបង ចុះបងមានចងចាំថាបងកើតនៅឆ្នាំច័ន្ទគតិហាស បងឆ្នាំអីគេដែរទៅបង លក្ខណះឆ្នាំជូត ឆ្លូវ ខាល ថោះហាសបង?

ខ៖ ខ្ញុំកើតនៅឆ្នាំមមែ

កៈ ចឹងបងឆ្នាំមមែណាបង ចុះសំរាប់ថ្ងៃខែនឹងបងមានដឹងថាបងកើតនៅថ្ងៃខែអីគេទេបង?

ខៈ ខ្ញុំដូចជាអត់ចងចាំទេនឹងហាស

កៈ អូ៎!!បាទបង ចុះសំរាប់បងកើតនៅណាដែរបង?

ខៈ ខ្ញុំកើតនៅខេត្តស្វាយរៀងនឹងហាស

កៈ នៅខេត្តស្វាយរៀង ចុះនៅភូមិអី ឃុំអីគេដែរបង?

ខៈ នៅឃុំកំពង់ត្រែ នៅស្រុករមាសហែក ខេត្តស្វាយរៀងនឹងហាស

កៈ ចុះភូមិអីគេដែរទៅបង?

ខៈ នៅភូមិខ្លូលោត

កៈ នៅភូនខ្លូលោតណាបងណា?

ខៈ បាទនៅភូមិខ្លូលោតនឹងហាស

កៈ បាទបង ចុះបងមានចងចាំចំនួនប៉ុន្មាននាក់ដែរបង?

ខៈ ខ្ញុំមានបងប្អូនចំនួន6នាក់នឹង

កៈ ចុះបងជាកូនទីប៉ុន្មានដែរបង?

ខៈ ខ្ញុំជាកូនទី1នឹង

កៈ ចុះមានស្រីប៉ុន្មាននាក់ដែរ នឹងប្រុសប៉ុន្មាននាក់ដែរទៅបង?

ខៈ ខ្ញុំមានស្រី3នាក់ នឹងប្រុស3នាក់នឹងហាស

កៈ ចុះប្អូនៗៗរបស់បងនឹងមានឈ្មោះអីគេដែរទៅបង?

ខៈ នឹងមានឈ្មោះសំរិទ្ធិ មិនា

កៈ នឹងប្អូនរបស់បងទី2ណាបង?

ខៈ នឹងប្អូនទី2នឹងហាស

កៈ ចុះប្អូនទី3វិញបងឈ្មោះអី?

ខ៖  ទី3មួយទៀតនឹងមានឈ្មោះថា សំរិទ្ធិ នាត

ក៖  មានឈ្មោះសំរិទ្ធិនាត?

ខ៖  ហើយនឹងឈ្មោះ សំរិទ្ធិ ពេន មួយទៀតនឹងឈ្មោះសំរិទ្ធិ តាកុប
មួយទៀតនឹងមានឈ្មោះ សំរិទ្ធិ ញូមនឹងហាស

ក៖  អូ៎!!ពៅគេហោសបង?

ខ៖  បងគេតើទី2នឹងហាស

ក៖  ចុះបងមានធ្លាប់ចងចាំអនុស្សាវរីយ៍អីដែរទេ
បងធ្លាប់បានលេងអីជាមួយបងប្អូនរបស់បងដែរទេ កាលពីនៅក្មេងៗហាស?

ខ៖  ធ្លាប់បានលេងដែរនឹងលេងទឹកលេងអីនឹងហាស

ក៖  អូ៎!!លេងទឹកមែនទេបង ចុះមានធ្លាប់ទៅស្រែ លេងបិទពួនអីជាមួយគ្នាដែរទេ?

ខ៖  ធ្វើស្រែធ្វើអីនឹងហាស ធ្វើស្រែឡើងពីយប់ៗទៅធ្វើស្រែនឹងហាស

ក៖  បងមានធ្លាប់លេងបិទពួន លេងឡឹកបាយឡអីជាមួយគ្នាដែរតើហីបង?

ខ៖  ធ្លាប់លេងដែរនឹង

ក៖  ធ្លាប់លេងលោតកៅស៊ូអី លេងអីផ្សេងទៀតដែរតើហីបង?

ខ៖ ធ្លាប់លេងជាមួយប្អូនអីនឹងហាស

ក៖  អូ៎!!បាទបង ចុះបងចូលចិត្តលេងអីគេដែរជាមួយបងប្អូនរបស់បងដែរនឹងហោសបង?

ខ៖  ធ្លាប់លេងអីទេ លេងលោតកៅស៊ូអីនឹងកាលពីនៅក្មេងៗនឹងហាស

ក៖  មានលេងបាញ់ឃ្លីលេងអីចឹងទៅណាបង?

ខ៖  នឹងហើយលេងបាញ់ឃ្លីលេងអីនឹងហាស

ក៖  អូ៎!!បាទបង ចុះបងគិតថាប្អូនរបស់បងនឹងសព្វថ្ងៃគាត់នៅណាដែរទៅបង?

ខ៖  គាត់នៅល្វប្រាំនឹង

កៈ នៅណុងទាំងអស់គ្នារឺមួយក៏នៅលូប្រាំនឹងតែម្នាក់ទេបង?

ខៈ នៅពីរនាក់នឹងហាស

កៈ ចុះនាក់ផ្សេងទៀតគាត់នៅណាដែរទៅបង?

ខៈ នៅបន្ទាយមានជ័យម្នាក់ នឹងនៅរតនៈគីរីម្នាក់នឹងហាសនៅឆ្ងាយៗណាស់

កៈ អូ៎!!នៅឆ្ងាយពីគ្នាទាំងអស់ហោសបង?

ខៈ នៅឆ្ងាយពីគ្នាណាស់នឹង

កៈ ប៉ុន្តែពួកគាត់មានគ្រួសារអស់នៅបង?

ខៈ មានដែរហើយនឹង

កៈ ចុះអ្នកនៅលូប្រាំនឹងគាត់ធ្វើអីគេដែរទៅបង?

ខៈ គាត់ធ្វើការងាររោងចក្រនឹងហាស

កៈ គាត់ធ្វើការងាររោងចក្រ ចុះនៅបន្ទាយមានជ័យគាត់ធ្វើការងារអីគេដែរទៅបង?

ខៈ គាត់ធ្វើចំការនឹង

កៈ ចុះនៅខាង?

ខៈ សុទ្ធតែធ្វើចំការទាំងអស់នឹង

កៈ នៅខាងមណ្ឌលគិរីហីបង?

ខៈ បាទនឹងហើយ

កៈ ចុះឪពុករបស់ឪពុករបស់បងមានឈ្មោះអីគេដែរទៅបង?

ខៈ គាត់មានឈ្មោះសំរិទ្ធិ សាម៉ុល

កៈ អូ៎!!មកដល់ឥឡូវនឹងគាត់ប្រហែលជាអាយុប៉ុន្មានដែរបងមានចងចាំទេ?

ខៈ គាត់ប្រហែលជាអាយុ60ឆ្នាំហើយយ៉ាង

កៈ ប៉ុន្តែគាត់នៅរស់សព្វថ្ងៃនឹងហោសបង?

ខ៖ គាត់ស្លាប់បាត់ហើយនឹងនៅតែម្ដាយនឹង

ក៖ ចុះឪពុករបស់បងគាត់កើតនៅណាដែរបងមានដឹងទេ?

ខ៖ គាត់កើតនៅព្រៃវែង

ក៖ ចឹងគាត់នៅព្រៃវែងហោសបង ចុះម្ដាយរបស់បងនឹងគាត់មានឈ្មោះអីគេដែរទៅបង?

ខ៖ គាត់មានឈ្មោះម៉ៅ សាន

ក៖ ចុះគាត់កើតនៅ?

ខ៖ គាត់កើតនៅស្វាយរៀងនឹង

ក៖ គាត់កើតនៅខេត្តស្វាយរៀងចុះម្ដាយរបស់បងនឹងកាត់នៅរស់សព្វថ្ងៃនឹងហោសបង?

ខ៖ បាទនៅរស់នឹង

ក៖ ប៉ុន្តែគាត់អាយុប៉ុន្មានទាល់ឥឡូវនឹងហាសបងមានចងចាំទេ?

ខ៖ ដូចជាអាយុ57-58ឆ្នាំហើយនឹង

ក៖
អ៊ូ!!ចុះកាលពីឪពុករបស់បងគាត់នៅរស់នឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរហោសបង
?

ខ៖ កាលណុងគាត់ដូចជាធ្វើការនៅស្រុកនឹង

ក៖ អ៊ូ!!ធ្វើការងារនៅស្រុកហោសបង?

ខ៖ គាត់ធ្វើខាងក្រសួងអប់រំនឹង

ក៖ គាត់ធ្វើខាងក្រសួងអប់រំណបង សំរាប់ចិញ្ចឹមក្រុមគ្រួសារហោសបង
ប៉ុន្តែគាត់ធ្វើស្រែដែរតើហីបង?

ខ៖ គាត់ធ្វើស្រែដែរនឹង គាត់ដើរអើរគាត់ពិបាកណាស់និយាយរួមទៅនឹង
គាត់លក់ទឹកត្នោតអីនឹងហាស

ក៖ អ៊ូ!!បាទបង ចុះគាត់កាចរឺមួយក៏គាត់ស្លូតដែរបង?

ខ៖ គាត់ស្លូតដែរទេ

ក៖ អូ៎!!ចុះម្ដាយរបស់បងវិញគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរបង?

ខ៖ គាត់នៅផ្ទះនឹងដើរអត់រួចទេគាត់ឈឺនឹងហាស

ក៖ ប៉ុន្តែកាលពីមុននឹងហាស?

ខ៖ ពីមុននឹងគាត់ធ្វើស្រែធ្វើអីនឹងហាស គាត់ធ្វើចំការអីនឹងហាស

ក៖ អូ៎!!បាទបង ចុះម្ដាយរបស់បងគាត់ស្លូត រឺមួយក៏កាចដែរបង?

ខ៖ គាត់ស្លូតណាស់

ក៖ គាត់ស្លូតដែរណាបង?

ខ៖ គាត់អត់ចេះមាត់អីទេ

ក៖ ចុះបងមានចងចាំសាច់រឿងអីកាលពីបងនៅជាមួយឪពុកម្ដាយរបស់បងហាស ដូចថាចងចាំសាច់រឿងថាធ្លាប់បានធ្វើអីគេខ្លះជាមួយគាត់ដែរទេ?

ខ៖ កាលពីនៅក្មេងៗនឹងពិបាកណាស់ចុះយើងរកល្ងាចខ្វះព្រឹក រកព្រឹកខ្វះល្ងាចនឹងណាស់

ក៖ អូ៎!!ចឹងហោសបង ចុះពេលនឹងបងនឹងក្រុមគ្រួសរនឹងនៅខេត្តស្វាយរៀងហើយណាបង?

ខ៖ នៅខេត្តស្វាយរៀងនឹងហាសចុះនៅតូចៗនឹងហាស

ក៖ ប៉ុន្តែពេលណុងបងធ្វើអីគេខ្លះដែរទៅបង លក្ខណះដើរទៅរកស៊ីរកអីនឹងហាស?

ខ៖ ដើរទៅដាក់ត្រីដាក់អីចឹងហាស រកត្រីរកអីនឹងមានរកអីទេ

ក៖ អូ៎!!បាទបងបាទ?

ខ៖ ចុះពេលណុងមានចេះរកអីទេ

ក៖ ប៉ុន្តែរកបានយកទៅលក់នៅផ្សារណាបង?

ខ៖ យកមកលក់នៅផ្ទះនឹងលក់នៅតែផ្ទះនឹងហាស

កៈ អូ៎!!បាទ
ចុះបងគិតថាឪពុករបស់បងនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់ទៅបងដែរទេ?

ខៈ កាលពីក្មេងនឹងគាត់រៀនពូកែនឹងហាស

កៈ ចឹងគាត់រៀនពូកែ ប៉ុន្តែគាត់ធ្វើការងារអីគេខ្លះដែរទៅបង គាត់មានធ្លាប់ប្រាប់ដែរទេ

ខៈ គាត់ធ្វើជាទាហ៊ាននឹង

កៈ ចឹងគាត់ធ្វើជាទាហ៊ានមែនទេបង?

ខៈ គាត់ទៅដល់សមុទ្រទឹកខៀវហោស

កៈ អូ៎!!ចឹងហោសបង?

ខៈ គាត់ទៅដល់វៀតណាមហោស ដល់ពេលមកវិញនឹងគាត់មានបានអី

កៈ អូ៎!!ចុះម្តាយរបស់បងនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅបងដែរទេ?

ខៈ គាត់ធ្វើតែស្រែនឹងគាត់គ្មានធ្វើអីទេធម្មតានឹង

កៈ អូ៎!!យាយតាខាងឪពុកនឹងបងមានស្គាល់ឈ្មោះគាត់ដែរទេបង?

ខៈ ខ្ញុំស្គាល់ដែរនឹង

កៈ គាត់មានឈ្មោះអីគេដែរហោសបង?

ខៈ តាឈ្មោះផន ប៉ុន្តែយាយភ្លេចឈ្មោះបាត់ហើយមិនដឹងថាគាត់មានឈ្មោះអីគេដែរទេ

កៈ អូ៎!!បាទបង ចុះយាយតាខាងម្តាយបងស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ គាត់មានឈ្មោះពិសែម នឹងតាឈ្មោះ សុខ រឹក

កៈ អូ៎!!បាទចុះសំរាប់យាយតាខាងឪពុកនឹងគាត់កើតនៅណាដែរបងមានដឹងទេ?

ខៈ គាត់នៅខេត្តស្វាយរៀងនឹង

កៈ ចឹងគាត់កើតនៅខេត្តស្វាយរៀងហោសបង?

ខៈ គាត់នៅខេត្តស្វាយរៀងនឹងហាស

កៈ ចុះយាយតាខាងម្ដាយគាត់កើតនៅណាដែរបងមានដឹងទេ?

ខៈ អ៊ូ!!ខាងម្ដាយនៅខេត្តស្វាយរៀង ហើយខាងឪពុកនឹងនៅខាងព្រៃវែង

កៈ អ៊ូ!!បាទបងចុះបងមករស់នៅនឹងយូរនៅបង?

ខៈ ខ្ញុំមកនៅអស់9ឆ្នាំហើយនឹង

កៈ អស់9ឆ្នាំហើយណបង?

ខៈ បាទអស់9ឆ្នាំហើយនឹងហាស

កៈ ចុះដូចជាបងមានបងប្អូនរឺមួយក៏កូនចៅណាដែរទៅរស់នៅក្រៅប្រទេសទេបង?

ខៈ អត់មានទេ

កៈ ដូចជាបងប្អូនជីដូនមួយរឺមួយក៏កូនក្មួយអីដែរទៅធ្វើការងារនៅវៀតណាម
រឺនៅថៃអីចឹងហាសបង?

ខៈ មានមានក្មួយមួយនៅថៃ

កៈ ចុះគាត់ធ្វើអីគេដែរនៅថៃហាសបង?

ខៈ គាត់ធ្វើជាកម្មករនៅថៃនឹងដែរហាស

កៈ អ៊ូ!!ចុះសំរាប់ភរិយារបស់បងនឹងគាត់មានឈ្មោះអីគេដែរទៅបង?

ខៈ គាត់មានឈ្មោះញ៉ែម ប៊ុនធី

កៈ ចុះបងមានចងចាំថាបងរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅថ្ងៃខែឆ្នាំណាដែរទេបង?

ខៈ ខ្ញុំរៀបនៅឆ្នាំ2007នឹង

កៈ នៅឆ្នាំ2007 ហើយចុះនៅថ្ងៃខែបងមានចងចាំទេ?

ខៈ ដូចជានៅឆ្នាំ1981ហីប្រពន្ធរបស់ខ្ញុំហាស

កៈ អត់ទេថ្ងៃខែដែរបងបានរៀបអាពាហ៍ពិពាហ៍ហាសនៅថ្ងៃខែឆ្នាំណាដែរទៅបង?

ខៈ ខ្ញុំអត់បានចងចាំផងនឹង

កៈ ប៉ុន្តែដូចជានៅពេលដែរបងរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធរបស់បងនឹង តើបងជាអ្នករៀបចំដោយខ្លួនឯងរឺមួយក៏ឪពុកម្តាយរបស់បងគាត់ជាអ្នករៀបចំអោយដែរបង?

ខៈ ខ្ញុំជាអ្នករៀបដោយខ្លួនឯងនឹង

កៈ អូ្ន!!រៀបដោយខ្លួនឯងហោយបង?

ខៈ បាទនឹងហើយ

កៈ អូ្ន!!បាទបង ចុះបងមានជំនូនជូនប្រពន្ធរបស់បងដែរទេ?

ខៈ អត់អត់មានទេចុះមានអីកាលណុងទទេទាំងអស់នឹងហាស

កៈ
ចុះដូចជាបងស្គាល់ប្រពន្ធរបស់បងនៅពេលណាដែរបានបងចូលស្តីដណ្តឹងប្រពន្ធរបស់បងហើយដូចជារយៈពេលប៉ុន្មានដែរចឹងហាសបង?

ខៈ អស់ពីរទៅបីខែនឹងហាស

កៈ អូ្ន!!ចុះស្គាល់គ្នាដោយរបៀបណាដែរបង?

ខៈ រៀននៅសាលានឹងហាស

កៈ អូ្ន!!រៀននៅសាលាជាមួយគ្នាហោសបង?

ខៈ បាទៗនឹងហើយរៀនជាមួយគ្នានឹង

កៈ អូ្ន!!បាទបងចុះសំរាប់បងគិតថាបងរៀនបានថ្នាក់ទីប៉ុន្មានដែរបង?

ខៈ ខ្ញុំរៀនបានថ្នាក់ទី7រឺមួយថ្នាក់ទី8ទេនឹង

កៈ អូ្ន!!បងរៀនបានច្រើនដែរហើយនឹងរៀនបានថ្នាក់ទី7-8ហើយនឹង?

ខៈ បាទនឹងហើយ

កៈ ប៉ុន្តែកាលពិបងរៀននៅបងរៀននៅសាលាដែរទៅបង?

ខៈ វិទ្យាល័យសាលាក្រលះនឹងហាស

កៈ ប៉ុន្តែមានឈ្មោះអីគេដែរទៅបង?

ខៈ ដាក់វិទ្យាល័យសាលាក្រលះចឹងទៅ

កៈ ប៉ុន្តែនៅខេត្តស្វាយរៀងនឹងហោស?

ខៈ នៅខេត្តស្វាយរៀងនឹងហាស

កៈ អូ!!បាទបង ចុះបងមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេបង?

ខៈ អត់អត់មានចេះអីទេនឹង

កៈ ភាសាវៀតណាមអី ថៃអីបងអត់ចេះដែរណោះបង?

ខៈ អត់ចេះទេ

កៈ ចុះបងធ្លាប់មានមិត្តភក្តិដែរស្និទ្ធស្នាលដែរធំធាត់មកជាមួយគ្នាដែរទេបង?

ខៈ មានដែរតើ

កៈ ប៉ុន្តែដូចជាពួកគាត់មានឈ្មោះអីគេខ្លះៗដែរបងអាចរៀបរាប់ដែរបានទេ?

ខៈ មានឈ្មោះថាប៉ុន្តែឥឡូវនឹងគេធ្វើធំហើយនឹងហាស

កៈ អូ!!ប៉ុន្តែបងមានធ្លាប់ចងចាំអនុស្សាវរីយ៍អីជាមួយគាត់ដែរទេ?

ខៈ ចាំដែរនឹងកំសត់ដែរនឹង ធ្វើការជាមួយគ្នាធ្វើកម្មករគេគ្រប់ខេត្តដែរនឹងហាស

កៈ អូ!!ចឹងហោសបង?

ខៈ ប៉ុន្តែឥឡូវនឹងគេមានហើយគេមិនស្គាល់យើងទៀតទេនឹងហាស

កៈ អូ!!បាទប៉ុន្តែបងមានចងចាំថាធ្លាប់ទៅស្រែជាមួយគ្នាដែរតើហីបង?

ខៈ ធ្លាប់ទៅជក់បារីមួយដើមពីរនាក់អីក៏មានដែរនឹង

កៈ អូ!!ចឹងបានបងបាទ?

ខៈ ដេកជាមួយគ្នាដេកក្នុងអង្រឹងជាមួយគ្នាអីក៏មានដែរនឹង

កៈ អូ!!បាទបងបាទ?

ខ៖ តែឥឡូវនឹងគេមានៗៗអស់ហើយគេលែងស្គាល់យើងហើយនឹង

ក៖ ចុះគិតថាបងធ្លាប់ទៅធ្វើការងារនៅវាលស្រែដែរណាបង?

ខ៖ បាទធ្លាប់ដែរនឹង

ក៖ ប៉ុន្តែដូចជាបងទៅធ្វើការងារនៅវាលស្រែនឹងបងទៅធ្វើអីគេខ្លះដែរទៅបង?

ខ៖ ដាក់ទឹកស្រែលើកស្រែអីចឹងទៅ

ក៖ បាទបង ប៉ុន្តែមានការដកស្ទូងអីដែរណាបង?

ខ៖ បាទដកស្ទូងអីនឹងធ្វើតាមស្រុកតាមខេត្តអីនឹងហាស

ក៖ ចុះបងគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះហាស
តើបងធ្លាប់ធ្វើការងារអីគេខ្លះដែរទៅបង?

ខ៖ ភាគច្រើននឹងធ្វើសំណង់

ក៖ អូ៎!!ធ្វើសំណង់ហោសបង?

ខ៖ ហើយនឹងធ្វើអង់ទែន

ក៖ ចុះបងធ្លាប់ប្រកបមុខរបរបើកមុខជំនាញអីដែរទេបង?

ខ៖ ធ្លាប់ដែរបើកសំណង់នឹង

ក៖ អូ៎!!បងបើកដោយខ្លួនឯងនឹងហោសបង?

ខ៖ បើកខ្លួនឯងដែរប៉ុន្តែទៅវាមិនរួចនឹងហាស

ក៖ យើងទៅអត់រួចហោសបង?

ខ៖ យើងអត់មានទន់អោយគេនឹងហាស

ក៖ ចុះបងធ្លាប់ចិញ្ចឹមសត្វទេបង ចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមជ្រូក ចិញ្ចឹមគោអីនឹងហាស?

ខ៖ អត់ដែរចិញ្ចឹមទេ

កៈ អូ!!បាទបង ចុះបងគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះនឹង ជីវិតរបស់បងមានការផ្លាស់ប្តូរអីគេខ្លះអីគេខ្លះដែរទៅបង?

ខៈ មានការផ្លាស់ប្តូរដែរកាលពីមុននឹងពិបាកណាស់ ឥឡូវនឹងធម្មតា

កៈ ចុះបងគិតថាម្ហូបអីដែរបងចូលចិត្តដែរបង?

ខៈ មិនដឹងថាម្ហូបអីទេម្ហូបធម្មតារាល់ថ្ងៃនឹងហាសម្ហូបលាយតែគ្នានឹង

កៈ អូ!!បាទ ចុះបងគិតថាល្បែងប្រជាប្រិយ៍អីដែរបងគិតថាបងចូលចិត្តលេងដែរបង?

ខៈ លេងអង្គុញ ទាញព្រាត ចោលឈូងអីនឹង

កៈ លាក់កន្សែង នឹងដណ្តើមស្លឹកឈើអីនឹងហោសបង?

ខៈ បាទដណ្តើមស្លឹកឈើអីនឹងកាលនៅក្មេងៗៗនឹងហាស

កៈ អូ!!បាទបងគិតថាបងចូលចិត្តច្រៀងដែរទេបង?

ខៈ ចូលចិត្តច្រៀងដែរនឹង

កៈ លក្ខណៈបទបុរាណ រឺមួយបទសម័យដែរបងចូលចិត្ត?

ខៈ បទពីដើមនឹងហាស

កៈ ប៉ុន្តែបងចូលចិត្តច្រៀងនរណាគេដែរបង?

ខៈ ច្រៀងតាមនឹងហាស

កៈ ប៉ុន្តែបទចំរៀងនរណាគេជាអ្នកច្រៀងដែរបងចូលចិត្តច្រៀងនឹង?

ខៈ ស៊ិនស៊ីសាម៉ុតនឹងហាស

កៈ អូ!!ស៊ិនស៊ីសាម៉ុតនឹងហោសបង ប៉ុន្តែបងចូលចិត្តស្តាប់បទចំរៀងដែរទេបង?

ខៈ ខ្ញុំចូលចិត្តដែរតើនឹង

កៈ ប៉ុន្តែលក្ខណៈបងសម័យរឺមួយបទពីដើមដែរបង?

ខៈ បទពីដើមនឹងហាស

កៈ ចុះបងមាននរណាគេនៅក្នុងក្រុមគ្រួសារបងរបស់ចេះលេងឧបករណ៍ភ្លេងដែរទេបង?

ខៈ អត់មានផងនឹង

កៈ អូ៎!!បងប្អូនកូនក្មួយអីក៏អត់មានដែរណាបង?

ខៈ មានបងៗនឹងបងថ្លៃនឹងហាស

កៈ គាត់ចេះលេងអីគេដែរបង?

ខៈ គាត់ចេះលេងភ្លេងខ្មែរនឹងហាស

កៈ អូ៎!!លេងភ្លេងខ្មែរហោសបង?

ខៈ នឹងហើយលេងភ្លេងអកកណ្ដុងអីនឹងហាស

កៈ អូ៎!!ប៉ុន្តែខាងបងអត់ចេះទេ?

ខៈ អត់ចេះលេងទេនឹង

កៈ បាទបង
ចុះផ្ទះរបស់បងនឹងមានលក្ខណៈបែបណាដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាសបង
?

ខៈ អូ៎!!យ៉ាប់និយាយណាស់ផ្ទះវាយ៉ាប់ណាស់

កៈ អូ៎!!រៀងយ៉ាប់មែនទេបង?

ខៈ នឹងហើយវាយ៉ាប់តែម្ដងនឹងហាស មិនមែនរៀងយ៉ាប់ទេយ៉ាប់តែម្ដងនឹងហាស

កៈ អូ៎!!ប៉ុន្តែលក្ខណៈជាផ្ទះបែបលក្ខណៈបែបយ៉ាងម៉េចដែរបងផ្ទះចឹងដែររឺយ៉ាងណា?

ខៈ ផ្ទះធម្មតាមិនទាន់ហើយទេនឹង

កៈ ចុះនរណាគេជាអ្នកសាងសងដែរបង បងជាអ្នកសាងសងខ្លួនឯងរឺម៉េច?

ខៈ ខ្ញុំធ្វើដោយខ្លួនឯងនឹងហាស

កៈ អូ៎!!បងចេះធ្វើផ្ទះហោសបង?

ខ៖ បាទចេះដែរនឹង

ក៖ អូ៎!!ចុះនរណាគេជាអ្នកបង្រៀនអោយបងចេះធ្វើផ្ទះដែរបង?

ខ៖ ចេះតែលួចតំរិះពីគេនឹងហាស

ក៖ អូ៎!!យើងទៅមើលគេហើយលួចធ្វើតាមណាងបង?

ខ៖ នឹងហើយទៅមើលគេហើយធ្វើតាមនឹងហាស

ក៖ អូ៎!!បាទបងបាទ?

ខ៖ គ្មាននរណាធ្វើ

ក៖ ចុះផ្ទះរបស់បងនឹងគេប្រើឧបករណ៍អីគេសំរាប់សាងសងដែរបង?

ខ៖ ធ្វើពីថ្ម ខ្សាច់ នឹងឥដ្ឋអីនឹង បើយើងធ្វើផ្ទះឈើមានឈើអីនឹង

ក៖ អូ៎!!បាទបង ចុះបងគិតថាជំនាញអីដែរបងចេះស្ទាត់ជំនាញដែរបង?

ខ៖ ជំនាញនឹងធ្វើផ្ទះថ្មនឹងហាស

ក៖ ជំនាញនឹងធ្វើផ្ទះថ្មណាបងណា
ចុះឪពុកម្ដាយរបស់បងនឹងគាត់មានធ្លាប់បង្រៀនពីជំនាញអីទៅបងទេ?

ខ៖ គេអោយតែខំរៀននឹងហាស

ក៖ វេញវល្លិ៍ ឡើងត្នោតកូរស្ករត្នោតអីចឹងហាសបង?

ខ៖ អត់អត់មានចេះទេ

ក៖ អត់មានចេះទេណាបង ចុះបងអាចប្រាប់ពីពេលលំបាកបានទេ
ថាបងមានការលំបាកអីគេខ្លះដែរចឹងហាសបង?

ខ៖
លំបាកណាស់ហូបបាយនឹងក៏ហូបមិនដែរគ្រប់ដែរនឹងហាសកាលពេលណុងឆ្នាំកៅជាង
ហោស

ក៖ ចុះកាលពីក្មេងបងធ្លាប់មានការលំបាកអីគេដែរបង?

ខ៖ លំបាកសូម្បីតែសម្លនឹងក៏អត់មានបឺចេងក៏មានដែរ មកនៅជំនាន់1993អីនឹងហាស

ក៖ ចុះដូចជាកាលពីក្មេងៗបងធ្លាប់បានធ្វើអីគេខ្លះដែរទៅបង?

ខ៖ ចាំដែរនឹងកាលពីនៅក្មេងៗនឹងមិនសូវបានគិតដែរនឹងគិតតែរត់លេងនឹងហាស

ក៖ អូ៎!!ពេលណុងបងនៅជាមួយក្រុមគ្រួសាររបស់បងដែរហោសបង?

ខ៖ នៅនៅជាមួយម៉ែឪនឹងហាស

ក៖ អូ៎!!ហេ្វតមកដល់ឆ្នាំកៅជាងនឹងបងធ្វើអីគេដែរបង?

ខ៖ នៅរត់លេងមិនសូវចេះធ្វើអីគេដែរនឹង

ក៖ អូ៎!!ហេ្វតដល់ពេលណាដែរបងគិតថាជាពេលដែរលំបាកខ្លាំងតែម្តងនឹងហាស?

ខ៖ លំបាកខ្លាំងនៅឆ្នាំ1997-1998នឹងហាស

ក៖ ពេលណុងបងបានធ្វើអីគេដែរទៅនឹងហាស?

ខ៖ កាលណុងទៅរើសអេតចាយ

ក៖ ទៅរើសអេតចាយហោសបង?

ខ៖ នឹងហើយអេតចាយទៅលក់អេតចាយនឹង ទិញអេតចាយនឹងហាស

ក៖ ប៉ុន្តែពេលណុងនៅណាដែរទៅបង?

ខ៖ នៅខេត្តស្វាយរៀងនឹងដែរតើនឹង

ក៖ អូនៅខេត្តស្វាយរៀងហោសបង
ហេ្វតទាល់តែមានក្រុមគ្រួសារនឹងបងគិតថាបងលំបាកអីគេដែរបង?

ខ៖ ខ្ញុំលំបាកហេ្វតទាល់តែដល់អាយុ19ឆ្នាំនឹងហើយបានវារៀងធូរនឹងហាស

ក៖ ចុះបងមានក្រុមគ្រួសារនឹងនៅអាយុប៉ុន្មានដែរបង?

ខ៖ នៅអាយុ20ឆ្នាំនឹងហាស

ក៖ អូ!!នៅអាយុ20ហោសបង អូប៉ុន្តែពេលណុងបងមានការលំបាកអីផ្សេងទៀតទេបង ពេលដែរបងមានគ្រួសារដំបូងហាស?

ខ៖ វាលំបាកនឹងលំបាកហើយគ្មានបានមានផ្ទះគ្មានអីនៅទេ

ក៖ ប៉ុន្តែដូចថាបងចាប់ដៃគ្នារកស៊ីអីចឹងហោសបង?

ខ៖ បាទនឹងហើយ

ក៖ អូ!!បាទបង ចុះបងគិតថានិងឆ្លងកាត់ការលំបាកនឹងដោយរបៀបណាដែរទៅបង?

ខ៖
ដូចថាកាលណុងវាលំបាកទាំងអស់គ្នាតែម្តងនឹងម៉ែឪក៏ពិបាកខាងគ្រួសារក៏ពិបាកដែរនឹង មានការលំបាកទាំងអស់គ្នានឹងហាស

ក៖ អូ!!ចឹងត្រូវខំាំងអស់គ្នាណាបង?

ខ៖ បាទនឹងហើយចឹង

ក៖ ចុះបងគិតថាបងសព្វថ្ងៃនឹងបងមានកូនប៉ុន្មាននាក់ដែរទៅបង?

ខ៖ ខ្ញុំមានកូន5នាក់នឹងហាស

ក៖ ប៉ុន្តែកូនរបស់បងនឹងគាត់អាយុធំៗៗហើយណាបង?

ខ៖ ធំៗៗអស់ហើយនឹងអាយុ16-17ឆ្នាំនឹងហាស

ក៖ អូ!!ប៉ុន្តែឥឡូវនឹងពួកគាត់ទៅធ្វើការងារអស់ហើយណាបង?

ខ៖ ទៅធ្វើការងារនៅលូប្រាំនឹងហាស

ក៖ អូ!!បាទបង
ចុះបងគិតថាពេលណាដែរបងគិតថាសប្បាយដែរបងនៅក្នុងជីវិតរបស់បងហាស?

ខ៖
ទើបបានប៉ុន្មានពីរឆ្នាំនឹងហាសរៀងសប្បាយតិចក្រៅពីនឹងមិនសូវសប្បាយទេពិបាកតែរហូតនឹង

កៈ អូ៎!!ប៉ុន្តែបងកូនរបស់បងនឹងគាត់មានក្រុមគ្រួសារខ្លះនៅបង?

ខៈ នៅទេមិនទាន់មានទេ

កៈ ចឹងនៅទាំងអស់ណាបង?

ខៈ នៅទាំងអស់នឹងហាស

កៈ អូ៎!!បាទបង ចុះនៅពេលដែរបងរៀបអាពាហ៍ពិពាហ៍រឺមួយបងជួបជុំក្រុមគ្រួសារ តើបងគិតថាសប្បាយទេពេលណុងហាសបង?

ខៈ សប្បាយបានជួបគ្នាសប្បាយតែពេលណុង

កៈ អូ៎!!សប្បាយតែមួយភ្លេតនឹងហោសបង?

ខៈ
បាទសប្បាយតែមួយភ្លេងនឹងក្រៅពីនឹងទៅលែងសប្បាយហើយនឹងរួចប្រឹងទៀតទៅនឹង

កៈ ដូចបងគិតថាកាលពីក្មេងហាសបងធ្លាប់មានគិតស្រម៉ៃថាធំឡើងបងចង់ធ្វើអីគេដែរទេ កាលពីបងនៅរៀនអីចឹងហាស?

ខៈ ខ្ញុំស្រលាញ់តែខាងសំណង់ទេនឹង

កៈ អូ៎!!បងស្រលាញ់ខាងសំណង់ ហេតុអីបានជាបងស្រលាញ់ខាងសំណង់វិញបង?

ខៈ ខ្ញុំចូលចិត្តធ្វើចូលចិត្តតាំងពីតូចមកនឹងហាស

កៈ
អូ៎!!ប៉ុន្តែគោលដៅរបស់បងនឹងតើបងចង់ធ្វើអីគេដែរនៅខាងផ្នែកសំណង់នឹងហាសបង?

ខៈ ចង់ធ្វើជាអ្នកម៉ៅការសំណង់អីចឹងទៅប៉ុន្តែបច្ចេកទេសវាមិនដល់គេអីនឹងហាស

កៈ ដោយសារតែបងជំនាញនៅខាងធ្វើជាសំណង់មែនទេបង?

ខៈ បាទនឹងហើយ

កៈ ចឹងបងតែងតែស្រលាញ់ខាងសំណង់មួយនឹង
ចុះប្រពន្ធរបស់បងគាត់ធ្វើអីគេដែរទៅបង?

ខ៖ គាត់ធ្វើស្រែចំការចម្មតានឹងហាស

ក៖ ប៉ុន្តែនៅជាមួយបងសព្វថ្ងៃនឹងហោសបង?

ខ៖ បាទនឹងហើយបេះតហារកូនអីអោយគេចឹងទៅមួយថ្ងៃពីរបូម៉ឺនអីចឹងទៅ

ក៖ អូ្ន!!គាត់យកទៅលក់នៅផ្សារណាបង?

ខ៖ អត់ទេបេះស៊ីឈ្នួលគេអីនឹងហាស

ក៖ អូ្ន!!គាត់ទៅស៊ីឈ្នួលបេះអោយគេហោសបង?

ខ៖ បាទស៊ីឈ្នួលអោយគេនឹង

ក៖ ប៉ុន្តែនៅឆ្ងាយៗមែនទេរឺមួយក៏នៅម្តុំនឹងដែរ?

ខ៖ នៅឆ្ងាយៗដែរនឹងហាសជិះទូកមួយឆ្អេតដែរនឹងហាស

ក៖ អូ្ន!!ជិះទូកទៅបេះហោសបង?

ខ៖ ជិះទូកទៅបេះនឹងហាស

ក៖ បាទបង
ចុះបើសិនជាចង់អោយបងផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗតើបងចង់ផ្តែផ្តាំអីគេខ្លះដែរទៅពួកគាត់ហាសបង?

ខ៖ ផ្តែផ្តាំអោយតែប្រឹងរៀនសូត្រទៅកុំអោយតែពិបាកដូចខ្ញុំពីមុនចឹងហាស
អោយរៀនសូត្រចេះដឹងទៅរកការងារបានល្អៗចឹងទៅវាស្រួលចឹងហាស

ក៖ អូ្ន!!ចុះបើសិនជាចង់អោយពួកគាត់ជៀសវៀងវិញហាស
តើបងចង់អោយពយកគាត់ជៀសវៀងអីគេដែរវិញទៅបង?

ខ៖ ជៀសវៀងកុំអោយជក់គ្រឿងញៀនកុំអោយអីចឹងទៅនឹង
កុំអោយមើលអ្នកជក់គ្រឿងញៀននឹង
ពិបាកដល់ហើយនឹងក្មេងៗឥឡូវនឹងវាពិបាកណាស់នឹង

ក៖ អូ្ន!!បាទបងបាទ?

ខ៖ ខ្លះដើរស្រែខ្លះដើរហួរចឹងទៅវាពិបាកដែរនឹងហាស

ក៖ វាពិបាកខាងខូចសតិអារម្មណ៍ណាបង?

ខ៖
វាធឹកទៅឡូឡាទៅពិបាកបន្តិចពិបាកម៉ែឪវានឹងហាសមើលនៅផ្ទះជិតៗៗនឹងខ្ញុំឃើញច្រើន
ណាស់

ក៖ ចុះបងមានអីចង់ផ្ដែផ្ដាំផ្សេងទៀតទេដើម្បីអោយពួកគាត់អាច
អោយពួកគាត់មានការងារល្អខំប្រឹង
រៀនចឹងទៅអោយមានការងារល្អដើម្បីសំរេចគោលបំណងរបស់បងអីចឹងហាសបង?

ខ៖ បើរៀនទៅបានសម្រេចនៅការងារល្អហើយនឹង

ក៖ ចុះបងធ្លាប់គិតថាកូនរបស់បងនឹងចង់អោយសម្រេចនៅគោលបំណងរបស់បងដែរទេ
រឺយ៉ាងម៉េចដែរ?

ខ៖ នឹងហើយចង់អោយបានសំរេចដូចតែគ្នានឹងហាស
អោយខំប្រឹងរៀននឹងអោយធំឡើងនឹងកុំអោយ ពិបាកដូចម៉ែដូចឪចឹងហាស

ក៖ អូ៎!!បាទបងបាទ ចុះមានអីផ្សេងទៀតទេបង?

ខ៖ អត់មានអីផ្សេងទៀតទេនឹង

ក៖ ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនបងដើម្បីអោយខ្ញុំពិភាក្សាជាមួយបងហើយ
នឹងបាននិយាយពីប្រវត្តិ
របស់បងជាមួយនឹងបងហើយនឹងបានដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរប
ស់សាលា
ដើម្បីតំកល់ទុកអោយបងពេលក្រោយៗៗដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗៗបានស្គា
ល់នឹងបានដឹងចឹងហាសបង?

ខ៖ បាទនឹងហើយ

ក៖
មួយទៀតខ្ញុំអរគុណបងហើយជាចុងក្រោយនឹងខ្ញុំជូនពរបងដើម្បីអោយបងមានសុភមង្គល
នៅក្នុង ក្រុមគ្រួសារ នឹងបងអាចរកស៊ីជាមួយប្រពន្ធរបស់បងអាចរកស៊ីរីកចំរើន

ហើយនឹងកូនរបស់បងនឹងអាចដើរទៅក្នុងកន្លងធិមរបស់បងដែរបងបានប្រាប់មិញចឹងហាសបង?

ខ៖ បាទនឹងមានតែចឹង

ក៖
ហើយនឹងអាចអោយគាត់មានគ្រួសារមួយដែរល្អនៅក្នុងសង្គមអោយពួកគាត់អាចរីកចំរើននៅក្នុង សង្គមដែរចឹងហាសបង?

ខ៖ បាទៗនឹងហើយ

ក៖
ហើយចឹងមួយទៀតនឹងខ្ញុំជូនពរបងអោយរីកចំរើនទាំងក្រុមគ្រួសារទាំងបងប្អូនទាំងអស់អីចឹងហាស បងចឹងអរគុណច្រើនហាសបង៕៕៕